# ព្រះរាជក្រម

នស/រកម/០២០២/០០៩

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអ៊ុយនីឌ្រ័រស្តីពីសម្បត្តិវប្បធម៌ ដែលត្រូវគេលួច ឬត្រូវគេធ្វើនីហរណកម្មខុសច្បាប់ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ប៉ុន្តែដែលព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ ព្រោះព្រឹទ្ធសភាពុំអាចដំណើរការប្រជុំពិនិត្យច្បាប់នេះបាន ដោយមូលហេតុខ្វះកូរ៉ុម ។ ច្បាប់នេះមានសេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើអនុសញ្ញាអ៊ុយនីដ្រ័រ ស្តីពីសម្បត្តិវប្បធម៌ ដែលត្រូវគេលួច ឬត្រូវគេធ្វើនីហរណកម្មខុសច្បាប់

មាត្រា ១.-

អនុម័តយល់ព្រមលើអនុសញ្ញាអ៊ុយនីដ្រ័រ ស្តីពីសម្បត្តិវប្បធម៌ដែលត្រូវគេលួច ឬត្រូវគេធ្វើនីហរណកម្មខុសច្បាប់ ដែលបានចុះហត្ថលេខា នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅទីក្រុងរ៉ូម នៃសាធារណរដ្ឋអ៊ីតាលី ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

នស/រកម.០២.០២.០០៥៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី លេខ : ៥២ ច.ល

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីចម្លងចែក

ព្រះហស្តលេខា រាជធានីភ្នំពេញ . ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០២

នរោត្តម បុប្ផាទេវី អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង៉ី តាន់